**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

* * * * * * * * * * * * *

**កិច្ចព្រមព្រៀង**

**រវាង**

**ក្រុមហ៊ុន យ៉ុង ដេ វ៉ី ហ្គាមេន ភីធីអ៊ាយ អិលធីឌី**

**ជាមួយតំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំក្រុមហ៊ុន**

នៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០២៣ វេលាម៉ោង ១២ និង ៣០ នាទី រសៀល នៅក្នុងរោងចក្រ

**យ៉ុង ដេ វ៉ី ហ្គាមេន ភីធីអ៊ាយ អិលធីឌី**

មានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិត ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់ស្តីពីស្ថានភាពបច្ចុប្បន្ននៃក្រុហ៊ុនយើងខ្ញុំខ្វះការបញ្ជាទិញ ដែលបណ្តាលឲមានការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតមួយចំនួន។ ហេតុដូចនេះក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ៣៦នាក់ (ស្រី ២៦នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៩១៤នាក់ ( ស្រី ៦៦៩នាក់ ) រយៈពេល ៣១ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។ ក្នុងកំឡុងពេលព្យួរកិច្ចសន្យាកាងារកម្មករនិយោជិតបានឯកភាពគ្នាពីតំណាងក្រុមហ៊ុន យ៉ុង ដេ វ៉ី ហ្គាមេន ភីធីអ៉ាយ អិលធីឌី និងតំណាងកម្មករនិយោជិតទាំងអស់។ ចំពោះការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតក្រុមហ៊ុនបានផ្តល់ជូនប្រាក់ឧត្ថម្ភ ៣០ ដុល្លាក្នុងមួយខែ ដោយមានការឯកភាពពីតំណាងកម្មករនិយោជិតទាំងអស់។

ប្រាក់ឧបត្ថម្ភក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះនិងបើកជូនបងប្អូនកម្មករនៅថ្ងៃទី២៥ខែវិច្ឆិកាឆ្នាំ២០២៣។

អង្គប្រជុំបានចប់នៅវេលាម៉ោង ១៣ និង ១០នាទីរសៀលនាថ្ងៃខែឆ្នាំដដែរប្រកបដោយបរិយាកាសរីករាយនិងស្និតស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោគយល់សហការគ្នាយ៉ាងរលូន ។

ថ្ងៃសុក្រ ១២កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០២៣

**តំណាងក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន យ៉ុង ដេ វ៉ី ហ្គាមេន ភីធីអ៊ាយ អិលធីឌី YONG DE WEI GARMENT PTY LTD. KINGDOM OF CAMBODIA

**ស្នាមមេដៃតំណាងកម្មករ និយោជិត**

វ៉ត្ត វលក្ខ័ គិន សុជាតិ ប៉ាន់ សុភា គួន ចាន់ យី បូណាន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**នាយកក្រុមហ៊ុន យ៉ុង ដេ វ៉ី ហ្គាមេន ភីធីវ៉ាយ អិលធីឌី**

YONG DE WEI GARMENT PTY LTD

**សូមគោរពជូន**

**លោកប្រធាននាយកដ្ឋានអធិការកិច្ចការងារ**

**កម្មវត្ថុ៖** ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិករយៈពេល៣១ថ្ងៃចាប់គិតពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០២៣ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ។

**យោង៖** មាត្រា៧១ និងមាត្រា៧២ នៃច្បាប់ស្តីពីការងារ ។

សេចក្តីដូចបានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថា បច្ចុប្បន្នក្រុមហ៊ុនយើងខ្ញុំកំពុងជួបបញ្ហាសេដ្ឋកិច្ចសកល ដែលបណ្តាលឱ្យក្រុមហ៊ុនយើងខ្ញុំខ្វះការបញ្ជាទិញ ដូច្នេះក្រុមហ៊ុនមិនមានការងារគ្រប់គ្រាន់សម្រាប់បងប្អូននិយោជិកធ្វើឡើយ។ ដូច្នេះក្រុមហ៊ុនសម្រេចព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ៣៦នាក់ ( ស្រី ២៦នាក់ ) ក្នុងចំណោមកម្មករយោជិតសរុបចំនួន ៩១៤នាក់ ( ស្រី ៦៦៩នាក់ ) រយះពេល ៣១ថ្ងៃ ដោយចាប់គិតពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៣ ដល់ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៣ ។

អាស្រ័យហេតុនេះ សូម **លោកប្រធាន** មេត្តាអនុញ្ញាតឲក្រុមហ៊ុនយើងខ្ញុំបានព្យួរកិច្ចសន្យាការងារកម្មករនិយោជិកដោយក្តីអនុគ្រោះ ។

សូម **លោកប្រធាន** ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ថ្ងៃសុក្រ ១២កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០២៣

**នាយកក្រុមហ៊ុន**